គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

# សេចក្តីថ្លែងការណ៍របស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

*"ការបិទព្រំដែនជាឯកតោភាគី នាំឱ្យមានការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ"*

តាមរយៈបណ្តាញសារព័ត៌មាននានា ក៏ដូចជាប្រជាពលរដ្ឋរស់នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និង ភ្ញៀវទេសចរណ៍ ដែលឆ្លងកាត់ព្រំដែនប្រទេសទាំងពីរ គណៈកម្មាធិការការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក.) សូមសម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះការបិទព្រំដែនជាឯកតោភាគីរបស់ប្រទេសថៃនាពេលថ្មីៗនេះ។ ការបិទព្រំដែនភ្លាមៗ និងមិនបានជូនដំណឹងជាមុននេះ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិមនុស្ស និង សេរីភាពមូលដ្ឋាន រួមមាន៖

១. **សេរីភាពក្នុងការធ្វើដំណើរ៖** ការបិទព្រំដែនដោយឯកភាគីរបស់ថៃ បានបង្កឲ្យមនុស្សជាច្រើន រួមមាន កម្មករ ពាណិជ្ជករ អ្នកធ្វើដំណើរឆ្លងកាត់ និងគ្រួសារជាច្រើន ត្រូវបានជាប់គាំង និងមិនអាចធ្វើដំណើរ ឆ្លងព្រំដែនបាន ។ ការណ៍នេះ បានរំលោភដល់សេរីភាពក្នុងការធ្វើដំណើរ ដែលជាសេរីភាពជាមូលដ្ឋាន ចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (មាត្រា១៣) និងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (មាត្រា១២)។

២. **សិទ្ធិមានជីវភាពរស់នៅសមរម្យ៖** ការបិទព្រំដែនភ្លាមៗបែបនេះ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ ប្រជាពលរដ្ឋ ដែលធ្វើដំណើរឆ្លងកាត់ព្រំដែនប្រចាំថ្ងៃដើម្បីប្រកបរបរចិញ្ចឹមជីវិត រួមមាន ពាណិជ្ជករ កម្មករ និងអ្នកប្រកបអាជីវកម្មតូចៗ។ ពួកគាត់នឹងបាត់បង់ប្រភពចំណូលចម្បង ដែលនឹងបង្ក ឱ្យមានការលំបាកផ្នែកហិរញ្ញវត្ថុ ការហូបចុក ផ្ទះសម្បែង និងសុខភាពផ្លូវចិត្ត។ សិទ្ធិនេះត្រូវបាន ការពារដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (មាត្រា១១)។

៣. **សិទ្ធិមានការងារធ្វើ៖** ការបិទព្រំដែនជាឯកតោភាគីដោយប្រទេសថៃ បានរាំងពលករទេសន្តរប្រវេសន៍ មិនឱ្យទៅធ្វើការងារ។ ការណ៍នេះ គឺជាការរំលោភសិទ្ធិមានការងារធ្វើ ដែលមានចែងក្នុងសេចក្តីប្រកាស ជាសកលស្តីពីសិទ្ធិមនុស្ស (មាត្រា២៣) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ (មាត្រា៦)។

៤. **សិទ្ធិទទួលព័ត៌មាន៖** អ្នកធ្វើដំណើរ ពាណិជ្ជករ និងកម្មករ រាប់ពាន់នាក់ ត្រូវបានជាប់គាំងនិង ជ្រួលច្របល់នៅតាមព្រំដែន ដោយសារការបិទព្រំដែនជាឯកតោភាគីពីប្រទេសថៃ ដោយពុំបាន

ជូនដំណឹង ឬចេញសេចក្ដីប្រកាសផ្លូវការណាមួយជាមុន។ សិទ្ធិទទួលបានព័ត៌មានត្រូវបានធានាដោយកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (មាត្រា១៩)។

៥. **សិទ្ធិទទួលបានសុខភាព និងការអប់រំ៖** ទោះបីជាសិស្សានុសិស្ស និងអ្នកជំងឺត្រូវបានអនុញ្ញាតឱ្យឆ្លងព្រំដែនក៏ដោយ ក៏ពួកគេនៅតែជួបប្រទះបញ្ហាប្រឈមជាច្រើន ជាពិសេស អ្នកដែលមានបញ្ហាពាក់ពន្ធ័នឹងឯកសារផ្សេងៗ។ សិទ្ធិទាំងនេះ ត្រូវបានការពារដោយកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (មាត្រា១២ ១៣ និង១៤)។

៦. **ការជួញដូរមនុស្ស៖** នៅពេលដែលច្រកព្រំដែនដែលមានសុវត្ថិភាព និងស្របច្បាប់ ត្រូវបានបិទ នឹងបង្ខំឱ្យប្រជាពលរដ្ឋ ប្រើប្រាស់មធ្យោបាយឆ្លងកាត់ព្រំដែនខុសច្បាប់ ជាពិសេស កម្មករដែលកំពុងត្រូវការការងារធ្វើ ដែលនឹងបង្កើនហានិភ័យនៃការជួញដូរមនុស្ស ជាពិសេស ក្រុមជនងាយរងគ្រោះ ដូចជា ស្ត្រី កុមារ មនុស្សចាស់ និងជនមានពិការភាព ជាដើម។

ចំពោះព័ត៌មានបន្ថែម សូមទាក់ទងមកកាន់អ្នកនាំពាក្យរបស់ គ.ស.ម.ក. គឺ ឯកឧត្តម **ប៉ា ប៉ុណ្ណារ៉ាជា** (០១២ ៦៨៦ ៧៩៨) និង ឯកឧត្តម **ស្រ៊ាង ចិន្តា** (០៧៧ ៣៣៥ ៦៤៤)៕

ថ្ងៃព្រហស្បតិ៍ ១កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥

អគារលេខ៣ ផ្លូវ VI.13 ភូមិទួលសំពៅ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
Building #3, Street VI.13, Toul Kok Village, Sangkat Toul Sangke, Khan Russey Keo, Phnom Penh Tel: (855) 23 882 065